ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង Working Together for Positive Change
វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia

លេខ: ៤៧០១..../NGOF/២០១៦/DIP

**សូមគោរពជូន**
**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**
**ប្រធានរដ្ឋសភាជាតិ**

**កម្មវត្ថុ៖** សំណើពិនិត្យពិចារណាលើអនុសាសន៍នៃ សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៧ របស់អង្គការសង្គមស៊ីវិល។

តាងនាមឱ្យក្រុមការងារថវិកាជាតិនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ខ្ញុំបាទមានកិត្តិយសដ៏ខ្ពង់ខ្ពស់សូមគោរពជំរាបជូនសម្តេច អគ្គមហាពញាចក្រី មេត្តាជ្រាបថា ក្រុមការងារថវិកាជាតិបានធ្វើការរួមគ្នា ដើម្បីធ្វើការវិភាគ និងតាមដានលើការប្រមូលចំណូល និងការវិភាជន៍ថវិកាជាតិប្រចាំឆ្នាំ ដើម្បីចូលរួមចំណែកជាមួយនិងរាជរដ្ឋាភិបាល ក្នុងការពង្រឹងតម្លាភាពថវិកា និង ទំនាក់ទំនងជាមួយសាធារណជន ដែលជាផ្នែកមួយនៃកម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ដូចគ្នានេះដែរ ក្រុមការងារថវិកាជាតិបានធ្វើការវិភាគ និងផលិតនូវរបាយការណ៍សង្ខេបសំរាប់ការវិភាជន៍លើសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ដែលរួមមាន ការផ្តល់អនុសាសន៍ជូនអង្គសភាដើម្បីពិនិត្យមុននឹងធ្វើការអនុម័តលើសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ និងឆ្នាំបន្តបន្ទាប់ ដើម្បីធានាថា តម្រូវការរបស់ប្រជាពលរដ្ឋ ជាពិសេស កុមារ ស្ត្រី និង ជនងាយរងគ្រោះ ត្រូវបានឆ្លើយតប និង ចូលរួមចំណែកធ្វើឲ្យសម្រេចបាននូវការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំបាទ និងក្រុមការងារ សូមបញ្ជាក់អំពីឆន្ទៈដ៏មោះមុតរបស់យើងខ្ញុំ ក្នុងការគាំទ្រជានិច្ចដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល។ ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋសភាជាតិ ដែលកន្លងមកតែងតែបានផ្តល់កិច្ចសហប្រតិបត្តិការជាមួយក្រុមការងារ និងអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ជារៀងរាល់ឆ្នាំ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូមសម្តេច អគ្គមហាពញាចក្រី មេត្តាពិនិត្យពិចារណាទៅលើអនុសាសន៍ ដើម្បីធានាថា រាល់ច្បាប់ហិរញ្ញវត្ថុទាំងនេះ បានផ្តល់ធនធានគ្រប់គ្រាន់ដើម្បីឆ្លើយតបតម្រូវការប្រជាពលរដ្ឋក្នុងព្រះរាជាណាចក្រកម្ពុជា ដោយក្តីអនុគ្រោះ។

សូមសម្តេច អគ្គមហាពញាចក្រី មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំបាទ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦
ជ.ក្រុមការងារថវិកាជាតិ

NGO FORUM ON CAMBODIA

**តឹក វណ្ណារ៉ា**
នាយកប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

ចម្លងជូន៖
គណៈកម្មាធិការទី២នៃរដ្ឋសភា